## អរិយធម៌ ផូនីស្យា (Phoenicia civilization)

ផូនីស្យា (Phoenicia) គឺជាអរិយធម៌មួយដែលកកើតឡើងពីរដ្ឋឯករាជ្យ (City-states) ចំនួន០៤ រួមបញ្ចូលគ្នាដែលស្ថិតនៅក្នុងតំបន់សមុទ្រមីឌីទែរ៉ាណេ។ រដ្ឋទាំង០៤នោះ រួមមាន Tyre , Sidon , Byblos និង Baalbek ហើយសព្វថ្ងៃជាប្រទេស លីបង់ (Lebanan), ផ្នែកខ្លះនៃស៊ីរី ( Syria) និងផ្នែកខ្លះខាងជើងប្រទេសអ៊ីស្រាអែល (Northern Israel)[១] (រូបលេខ១)។

អរិយធម៌នេះកកើតដំបូងឡើងនៅ ឆ្នាំ ១៥០០មុនគ.ស. ដែលជាអរិយធម៌ និងអាណាចក្រដ៏ធំមួយនៅក្នុងតំបន់សមុទ្រមីឌីទែរ៉ាណេ។[២] ជនជាតិ ផូនីស្យា ត្រូវបានគេដឹងថាជាប្រជាជនដែលពូកែខាងដើរសមុទ្រ ក្នុងការជួញដូរ ធ្វើសង្គ្រាម ជាដើម។[៣] ចំពោះឈ្មោះ ផូនីស្យា (Phoenicia) នេះគឺចេញពីពាក្យ phoenix ក្នុងភាសាក្រិចបុរាណដែលមានន័យថាពណ៌ស្វាយ-ក្រហម ហើយសំដៅលើជនជាតិផូនីស្យា 'purple people'។[៤] ប្រព័ន្ធរដ្ឋបាលនៃអរិយធម៌នេះ គឺស្រដៀងទៅនឹងអរិយធម៌ក្រិច[៥] ដែរ ដោយពុំមានរដ្ឋបាលកណ្ដាល គឺមានតែការគ្រប់គ្រងដោយរដ្ឋឯករាជ្យទាំង៤។ ក្នុងចំណោមក្រុងទាំង៤នោះ ក្រុង Tyre, Sidon មានឥទ្ធិពលខ្លាំងជាងគេផ្នែកនយោបាយ និងសេដ្ឋកិច្ច។ រីឯក្រុង Byblos និង Baalbek គឺជារដ្ឋដែលសំខាន់ៗខាងផ្នែកវប្បធម៌ និងសាសនា។ គួរបញ្ជាក់ដែរថា សំណង់ស្ថាបត្យកម្ម វប្បធម៌ សាសនា នៃអរិយធម៌ផូនីស្យានេះគឺទទួលឥទ្ធិពលពីអរិយធម៌ក្រិចស្ទើរតែទាំងស្រុង (រូបលេខ២-៥)។

ទីក្រុង Tyre មានទីតាំងស្ថិតនៅខាងត្បូងនៃប្រទេសលីបង់ និងមានចម្ងាយប្រមាណជាង៨០គីឡូពីរាជធានី Beirut។ ទីក្រុងត្រូវបានកសាងឡើងនៅអំឡុងស.វ.ទី៣មុនគ.ស.

[១] https://www.worldhistory.org/phoenicia

[២] https://www.nationalgeographic.org/article/first-rulers-mediterranean

[៣] https://www.metmuseum.org/toah/hd/phoe/hd_phoe.htm

[៤] ibid

[៥] https://ams.com.kh/khmercivilization/detail/14061

អត្ថបទដោយ៖ អេង គុណា

ពោលកសាងក្នុងឆ្នាំ ២៧៥០មុនគ.ស. និងត្រូវបានដាក់បញ្ចូលក្នុងបេតិកភ័ណ្ឌពិភពលោក នៅក្នុងឆ្នាំ១៩៨៤។[៦] សំណង់ស្ថាបត្យកម្មនៅទីនេះ គឺដូចបានបញ្ជាក់ខាងលើហើយថា ជាឥទ្ធិពលនៃអរិយធម៌ក្រិច ដែលកសាងជាសសរទាំង៣ដូចនឹងរចនាបទនៅក្រិច ឬរ៉ូមាំង សម័យបុរាណ។ **Sidon** គឺជាឈ្មោះក្នុងភាសាក្រិច និងក៏ជាទីក្រុងដ៏សំខាន់នៃអរិយធម៌ផូនីស្យា។ ទីក្រុងនេះ មានទីតាំងស្ថិតនៅខាងជើងនៃប្រទេសលីបង់ និងមានចម្ងាយប្រមាណជាង ២០គីឡូពីរាជធានី **Beirut**។ ទីក្រុងនេះកកើតដំបូងនៅស.វ.ទី ៣មុនគ.ស. និងបានក្លាយជា តំបន់ពាណិជ្ជកម្មដ៏សំខាន់ក្នុងអរិយធម៌ផូនីស្យានាស.វ.ទី ៧មុនគ.ស។[៧] សំណង់ស្ថាបត្យកម្ម បុរាណជាច្រើនត្រូវបានរកឃើញនៅក្នុងតំបន់មួយហៅថា **Byblos** ដែលជាទីក្រុងចាស់ ជាងគេនៅក្នុងអរិយធម៌ផូនីស្យា ពោលមានការតាំងទីរស់នៅតាំងពីយុគថ្មបំបែក[៨] និង អំឡុងចុងស.វ.ទី ៤មុនគ.ស. តំបន់នេះបានក្លាយជាទីក្រុងផ្នែកសាសនាដ៏សំខាន់មួយនៅ ក្នុងអរិយធម៌ផូនីស្យា។[៩] ចំណែកឯទីក្រុង **Baalbek** គឺជាទីក្រុងដែលត្រូវបានគេដឹងថាទី ក្រុងដ៏សំខាន់ជាងគេខាងផ្នែកសាសនានៅក្នុងសម័យ **Hellenistic** ដែលជាសម័យកាលនៃ ការស្លាប់របស់ **Alexander the Great** ក្នុងតំបន់សមុទ្រមីឌីទែរ៉ាណេ[១០] ហើយជាទីក្រុងដែល ត្រូវបានអាណាចក្ររ៉ូមាំងគ្រប់គ្រង។[១១] នៅទីនេះសំណង់ស្ថាបត្យកម្មជាច្រើនសុទ្ធសឹងតែ ជាអរិយធម៌ **Greco-Roman** ជាពិសេសសំណង់សសរដ៏ធំ ដែលឃើញមាននៅតាមប្រាសាទ ព្រះវិហារ និងសំណង់សាធារណៈផ្សេងៗទៀត។[១២]

---

[៦] https://whc.unesco.org/en/list/299/gallery/&maxrows=36

[៧] https://en.unesco.org/silkroad/silk-road-themes/underwater-heritage/tyre-sidon-united-between-10th-and-9th-centuries-bc-divided

[៨] https://whc.unesco.org/en/list/295

[៩] https://www.britannica.com/place/Byblos

[១០] https://www.metmuseum.org/toah/hd/haht/hd_haht.htm

[១១] https://whc.unesco.org/en/list/294

[១២] ibid

អត្ថបទដោយ៖ អេង តុលា

ជនជាតិផូនីស្យាពូកែខាងផ្នែកសិល្បៈ ជាពិសេស រូបបដិមា/រូបចម្លាក់ (រូបលេខ៦-៨) ជាដើម។

ពល់ទន្និន័យទាំងអស់ដែលបានបង្ហាញខាងលើ និងតាមរយៈសំណង់ស្ថាបត្យកម្មសិល្បៈដែលបានបន្សល់ពីអរិយធម៌នេះបានបង្ហាញថា អរិយធម៌ផូនីស្យាត្រូវបានគេស្គាល់ថា ជាអរិយធម៌ដែលមានឥទ្ធិពលខ្លាំងក្លានៅក្នុងតំបន់សមុទ្រមីឌីទែរ៉ាណេ មានអាយុកាល ចាប់ពីឆ្នាំ ១៥០០មុនគ.ស. និងត្រូវបានដួលរលំនៅឆ្នាំ៣០០មុនគ.ស. ដោយអាណាចក្រក្បែរដែលរួមមាន **Cyrus**, ក្រិច និងរ៉ូមាំងជាដើម។[១៣]




រូបលេខ១៖ ផែនទីនៃវិសាលភាពអាណាចក្រផូនីស្យាសម័យបុរាណ

ប្រភព៖ https://www.classroomclipart.com

[១៣] https://courses.lumenlearning.com/atd-herkimer-westerncivilization/chapter/the-phoenicians/



រូបលេខ២ ៣ ៖ ទីក្រុង Tyre និងទីក្រុង Sidon

ប្រភព៖ https://www.civitatis.com/en/beirut/sidon-tyre-maghdouche-



អត្ថបទដោយ៖ អេង តុលា



រូបលេខ៤ ៥ ៖ ទីក្រុងបុរាណ Byblos និង Baalbek

ប្រភព៖ Internet



អត្ថបទដោយ៖ អេង តុលា



រូបលេខ៦ ៧ ៖ ចម្លាក់បង្ហាញពីផ្លូវទឹក និងការប្រើប្រាស់ទូកក្នុងអរិយធម៌ផូនីស្យា , រូបចម្លាក់សិល្បៈ ក្នុងអរិយធម៌នេះ

ប្រភព៖ Internet

